**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
-សាលក្រមព្រហ្មទណ្ឌលេខ ១៣៤ "ច"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ៦៩៧
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ១១៣៧
ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ៤១២៨
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅសាលាជម្រះក្តី នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃសុក្រ ១០កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ៣០នាទីព្រឹក។

**ដោយមានសមាសភាពដូចតទៅ**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៦៩៧ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៣៣២៧៦២ (០១) ទីកន្លែងកំណើត សង្កាត់បឹង[redacted] រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ A៤ ផ្លូវ១២ម៉ែត្រ បុរី PT ភូមិឈ្មាំង ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ[redacted] ណៃម "រស់" ម្តាយឈ្មោះ [redacted] ចាន់ថា "រស់" ប្រពន្ធឈ្មោះ [redacted] សោភ័ណ្ឌ "រស់" មានកូន០៣នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (នៅក្រៅឃុំ)

ជាប់ចោទពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D៥៤ ភូមិឈ្មាំង ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted] ជាមេធាវីនៃការិយាល័យមេធាវី [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ ០៤ ផ្លូវលេខ០១ (បុរីពិភពថ្មីចំការដូង) ភូមិសំបួរ សង្កាត់ធម្មង្គា ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

-មានលោក [redacted] ជាមេធាវីនៃការិយាល័យមេធាវី [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ ០៤ ផ្លូវលេខ២០១ (បុរីពិភពថ្មីចំការដូង) ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការផ្នែកទេសចរណ៍ខេត្តកំពង់ស្ពឺ កាន់សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានទីលំនៅបច្ចុប្បន្ននៅលេខ ៥ ភូមិជ្រៃកោង សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] លាង "រស់" ម្ដាយឈ្មោះ [redacted] ហុង "រស់" ប្រពន្ធឈ្មោះ [redacted] លីស៊ីម "រស់" មានកូន០២នាក់ ជានីតិជន។

-មានលោក [redacted] មានការិយាល័យនៅ ក្រុមមេធាវីជូនពេញ មានទីតាំងស្ថិតនៅផ្ទះលេខ ១១២B ផ្លូវលេខ១៧៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។

-មានលោក [redacted] មានការិយាល័យនៅ ក្រុមមេធាវី ពន្លឺ យុត្តិធម៌ មានទីតាំងស្ថិតនៅផ្ទះលេខ ១៣៦$E_0E_1$ ផ្លូវលេខ៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ បានទិញផ្ទះលេខ: D៥៤ ភូមិឈ្មាំង ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្ដាល ពីជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ក្នុងតម្លៃ ៤៨,៣០០ (បួនម៉ឺនប្រាំបីពាន់បីរយ) ដុល្លារអាមេរិក ហើយដើមបណ្ដឹងឈ្មោះ [redacted] ប៉ុកឆាយ បានប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ដោយជនជាប់ចោទបានអះអាងថានឹងសាងសង់ផ្ទះឱ្យដើមបណ្ដឹងឈ្មោះ [redacted] ប៉ុកឆាយ រួចរាល់ និងធ្វើវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុឱ្យឈ្មោះ [redacted] ប៉ុកឆាយ នៅខែមិថុនា ឆ្នាំ២០២១។ ផ្ទុយទៅវិញនៅពេលជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន បានទទួលប្រាក់ពីឈ្មោះ [redacted] ប៉ុកឆាយ គ្រប់ចំនួនហើយជនជាប់ចោទមិនបានធ្វើតាមការជានាអះអាងឡើយ ដោយផ្ទះមិនបានធ្វើ និងមិនទាន់ប្រគល់ប្លង់ផ្ទះឱ្យឈ្មោះ [redacted] ប៉ុកឆាយ នៅឡើយ ហើយជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន បានគេចវេសមិនព្រមជួបដើមបណ្ដឹងឡើយ។

បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៩០០ អ.យ.ណ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ ៣០១៦ "ខ១" ដ.ព.ស ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៣០១៧ "ខ១" ដ.ព.ស ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៦១៣ អ.យ.គ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៧១៧ "ខ១" ជ.ជ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ឯកសារផ្សេងៗដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង។

បានឃើញ ការផ្តល់ និងការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដែលធ្វើឡើង ដោយអនុលោមតាមបញ្ញត្តិមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>នាពេលសវនាការ</u>**

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស នៅចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយថា: ខ្លួនមានដីទំហំ ១២ហិចតា ដែលមានទីតាំងនៅភូមិឈ្នាំង ឃុំឈ្នាំង ស្រុកពញាឮ ខេត្តកណ្តាល ជាដីកម្មសិទ្ធិផ្ទាល់ខ្លួន។ ដីនេះមានប្លង់រឹងត្រឹមត្រូវ មានការបំបែកក្បាលដី។ ខ្លួនជាអគ្គនាយកក្រុមហ៊ុន ភីធី ប្រាក់ ចាន់ធឿន ឯ.ក ដែលជាម្ចាស់គម្រោងទី១ បុរីភីធី ទំហំ ១២ហិចតា ដែលមានទីតាំងនៅភូមិក្រាំង ឃុំឃ្លាំង ស្រុកពញាឮ ខេត្តកណ្តាល ខាងលើ។ គម្រោងនេះសាងសង់ ៤០០ផ្ទះ បានបើកនៅអំឡុងឆ្នាំ២០១៩ គម្រោងនេះលក់អស់ហើយ នៅសល់ប្រហែល១០ផ្ទះ ប៉ុណ្ណោះ។ បច្ចុប្បន្នអតិថិជនប្រហែល ១០០ផ្ទះ បានចូលរស់នៅ។ ដើម្បីធ្វើគម្រោងនេះខ្លួនបានខ្ចីប្រាក់ពីធនាគាររីង ចំនួន ៣,០០០,០០០ (បីលាន) ដុល្លារអាមេរិក ជាប្រាក់សម្រាប់សាងសង់សំណង់។ ខ្លួនបានប្រកាសលក់គម្រោងនេះសម្រាប់ឱ្យអតិថិជនទិញ ដោយមានជម្រើសពីរ ជម្រើសទី១គឺ អតិថិជនត្រូវបង់ផ្តាច់ដែលអាចទទួលបានការបញ្ចុះតម្លៃមួយចំនួន និងជម្រើសទី២ អតិថិជនត្រូវបង់ប្រាក់កក់៣០% ក្រោយពេលទទួលបានផ្ទះ និងទទួលបានប្លង់ត្រូវបង់ផ្តាច់បន្ថែម៧០% ទៀត។ ដោយសារតែសេដ្ឋកិច្ចមានការធ្លាក់ចុះ ព្រមទាំងមានបញ្ហាការរីករាលដាលជម្ងឺកូវីដ-១៩ ទើបធ្វើឱ្យមានការគាំងដំណើរការសងសង់។ បច្ចុប្បន្នគម្រោងនេះបានសាងសង់របងផ្ទះរួចរាល់ ហើយផ្ទះចំនួន១០០ផ្ទះ អតិថិជនបានចូលរស់នៅហើយ។ ដើម្បីដកប្លង់បានអតិថិជនត្រូវបង់ផ្តាច់ឱ្យខ្លួន និងអតិថិជនធ្វើសំណើទៅធនាគាររីងដើម្បីដកប្លង់ជូនអតិថិជន ដោយក្នុងនោះធនាគារត្រូវកាត់ប្រាក់ដែលអតិថិជនបង់ផ្តាច់ចំនួន ៣,០០០ (បីពាន់) ដុល្លារអាមេរិក ក្នុងមួយប្លង់ដើម្បីកាត់ប្រាក់ដើម ប្រាក់ដែលនៅសេសសល់ពីការកាត់ប្រាក់ដើមនេះ ជាចំណែករបស់ខ្លួនដែលត្រូវយកទៅចំណាយលើការសាងសង់បន្តផ្ទះរបស់អតិថិជនផ្សេងទៀត។ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ អតិថិជនឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស បានមកទិញផ្ទះលេខ D៥៤ ផ្លូវបុរីPT ភូមិឈ្នាំង ឃុំឈ្នាំង ស្រុកពញាឮ ខេត្តកណ្តាល ដោយបានបង់ប្រាក់ចំនួន ៣០% ស្មើនឹងចំនួន ១៣,២០០ (មួយម៉ឺនបីពាន់ពីររយ) ដុល្លារអាមេរិក។ ក្រោយមកដោយគ្មានលទ្ធភាពបង់បន្តកិច្ចសន្យាជាមួយបុរី អតិថិជនឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស បានលក់ផ្ទះនេះបន្តទៅឱ្យឈ្មោះ [redacted] ប៉ុកឆាយ ដោយឈ្មោះ [redacted] ប៉ុកឆាយ បានបង់ប្រាក់ថ្លៃទិញផ្តាច់មកបុរីយើងសរុបតម្លៃ ៤៨,៣០០ (បួនម៉ឺនប្រាំបីពាន់បីរយ) ដុល្លារអាមេរិក តែម្តង។ ដោយសារតែបញ្ហាជម្ងឺកូវីដ-១៩ និងបញ្ហាធ្លាក់ចុះនៃសេដ្ឋកិច្ច ធ្វើឱ្យការសាងសង់ផ្ទះនេះយឺតយ៉ាវ ស្រាប់តែអតិថិជនឈ្មោះ [redacted] ប៉ុកឆាយ បានដាក់ពាក្យបណ្តឹងមកតុលាការប្តឹងខ្លួនតែម្តង ការដាក់ពាក្យបណ្តឹងនេះធ្វើឡើងយូរមកហើយ។ បច្ចុប្បន្នអថិជនជាច្រើនបានទទួលយកផ្ទះស្នាក់នៅ ហើយទទួលបានប្លង់

មួយចំនួនរួចរាល់ហើយ។ បច្ចុប្បន្នផ្ទះរបស់ឈ្មោះ [redacted] ប៉ុកឆាយ បានសាងសង់រួចរាល់ ៧០% រួចហើយ។ ខ្លួនព្រមព្រៀងកាត់ប្លង់ជូនគាត់តាមនីតិវិធី សំណូមពរឱ្យដើមបណ្តឹងរដ្ឋប្បវេណីមកចរចារដោះស្រាយ ព្រោះខ្លួនអាចមានដំណោះស្រាយឱ្យគាត់ទទួលយកផ្ទះដែលសាងសង់រួច និងប្រគល់ប្លង់ ចំពោះការទាមទារសំណងខ្លួនគ្មានលទ្ធភាពទេ។ ខ្លួនសំណូមពរតុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបខ្លួន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

-តាមចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ ភេទប្រុស នៅដំណាក់កាលតំណាងអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរ ក៏ដូចនាពេលសវនាការនេះ បានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា: កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ខ្លួនបានទិញផ្ទះលេខ D៥៤ បុរីPT ផ្លូវD ភូមិឈ្មាំង ឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្តាល ពីឈ្មោះ [redacted] ចន្ធា និងប្រពន្ធឈ្មោះ [redacted] ស ក្នុងតម្លៃ ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយមានកិច្ចសន្យាទិញលក់អចលនវត្ថុ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។ នៅថ្ងៃនោះខ្លួន និងឈ្មោះ [redacted] ចន្ធា បានទៅបុរីPT ដើម្បីធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិជាមួយខាងបុរី ដោយសារឈ្មោះ [redacted] ចន្ធា និងប្រពន្ធឈ្មោះ [redacted] ស មិនទាន់បង់ប្រាក់ផ្តាច់ជាមួយបុរីនោះទេ។ នៅពេលនោះឈ្មោះ [redacted] ចន្ធា និងប្រពន្ធឈ្មោះ [redacted] ស បានបង់ប្រាក់ទៅខាងបុរីPT បានចំនួន ១៣,២០០ (មួយម៉ឺនបីពាន់ពីរយ) ដុល្លារអាមេរិក ស្មើនឹង ៣០% នៃតម្លៃទិញជាមួយបុរីចំនួន ៤៤,០០០ (បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក ដោយមានលិខិតផ្ទេរកម្មសិទ្ធិចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។ បន្ទាប់ពីធ្វើលិខិតផ្ទេរសិទ្ធិរួចខាងបុរីPT ក៏ធ្វើកិច្ចសន្យាលក់ដីឡូត៍-ផ្ទះវីឡា (អចលនទ្រព្យ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ជាមួយខ្លួន និងប្រពន្ធ ដោយលក់ក្នុងតម្លៃដើមចំនួន ៤៤,០០០ (បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក ដោយថ្ងៃនោះខ្លួនបានបង់ប្រាក់បង្គប់ឱ្យក្រុមហ៊ុន ចំនួន ៣០,៨០០ (បីម៉ឺនប្រាំបីរយ) ដុល្លារអាមេរិក ប៉ុន្តែក្រុមហ៊ុនបានបញ្ចុះតម្លៃ ៣,០០០ (បីពាន់) ដុល្លារអាមេរិក ដោយសារខ្លួនបង់ប្រាក់ផ្តាច់ ដូច្នេះនៅសល់ចំនួន ២៧,៨០០ (ពីរម៉ឺនប្រាំពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក ដោយមានវិក័យបត្របង់ប្រាក់បង្គ្រប់។ នៅក្នុងកិច្ចសន្យាលក់ដីឡូត៍-ផ្ទះវីឡា (អចលនទ្រព្យ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ជាមួយក្រុមហ៊ុន ភី.ធី ប្រាក់ចាន់ធឿន ឯ.ក វីឡាទោល (គម្រោងទី១) ឈ្មោះ [redacted] ចាន់ធឿន ជាអគ្គនាយកក្រុមហ៊ុន បានចុះហត្ថលេខា និងបោះត្រាក្រុមហ៊ុនជាមួយខ្លួន បានសន្យាតាមប្រការ៤ ថានឹងប្រគល់ផ្ទះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ រួមទាំងផ្ទេរសិទ្ធិកម្មសិទ្ធិពីឈ្មោះរបស់បុរីមកខ្លួនវិញ។ ប៉ុន្តែហួតដល់ពេលនេះផ្ទះមិនទាន់រួចទេ ហើយការផ្ទេរកម្មសិទ្ធិក៏មិនទាន់ធ្វើការផ្ទេរមកអោយខ្លួនដែរ។ នៅក្នុងអំឡុងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ខាងបុរីបានឱ្យខ្លួនបង់ប្រាក់ថ្លៃធ្វើដំបូលផ្ទះ (ខ្លួនកែផ្ទះដោយខ្លួនឯង) ចំនួន ៤,៣០០ (បួនពាន់បីរយ) ដុល្លារអាមេរិក ទៀត ដោយមានលិខិតបញ្ជាក់ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ដូច្នេះលុយដែលខ្លួនបង់ទៅក្រុមហ៊ុនមានចំនួនសរុប ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក។ បច្ចុប្បន្នខ្លួនបានទាក់ទងទៅខាងក្រុមហ៊ុន តែខាងក្រុមហ៊ុនបានគេចវេសហួត ដោយសន្យាសាងសង់ផ្ទះជូន ប៉ុន្តែផ្ទះមិនទាន់បានសាងសង់នោះទេ ទុកចោលហួតដល់បច្ចុប្បន្ន ដូចមានជាភស្តុតាងឯកសារជាប្រេចិតដែលខ្លួនបានដាក់ជូនក្នុងដំណាក់កាលអយ្យការរួចហើយ។ ក្នុងកិច្ចសន្យាគេអាចយឺតយ៉ាវក្នុងរយៈពេល ០២ខែ ហើយបើមានការយឺតយ៉ាវគេនឹងសងអត្រាការប្រាក់ ១២% នៃប្រាក់ដើម បច្ចុប្បន្នគឺយឺតយ៉ាវ ១ឆ្នាំ ១ខែ ហើយ ប៉ុន្តែសំណងក៏មិនមានដែរ ហើយការផ្ទេរកម្មសិទ្ធិផ្ទះក៏មិនមានទៀត ហើយអ្នកទិញ



Scanned with CamScanner

បុរីជាច្រើនក៏បានរកឃើញបុរី PT ដែរ។ ក្រុមហ៊ុនបុរី PT បច្ចុប្បន្នមិនទាន់បើក្រុមហ៊ុនទេ មានទីស្នាក់ការតូចនៅក្នុងបុរីនោះដដែល ប៉ុន្តែដំណើរការសាងសង់ផ្ទះគឺមិនមានទេ ហើយលុយទូទាត់សំណងទៅអ្នកទិញផ្ទះផ្សេងៗក៏មិនមានដែរ។ ខ្លួនសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ទាមទារប្រាក់ដើមចំនួន ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក, សំណងជំងឺចិត្ត និងការខាត់បង់ពេលវេលាចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។

**<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី</u>**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការនេះឃើញថា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ កូនក្តីខ្លួនបានទិញផ្ទះលេខ D៥៤ បុរីPT ផ្លូវD ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ពីឈ្មោះ [redacted] ចន្ថា និងប្រពន្ធឈ្មោះ [redacted] ស ក្នុងតម្លៃ ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយមានកិច្ចសន្យាទិញលក់អចលនវត្ថុ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។ នៅថ្ងៃនោះកូនក្តីខ្លួន និងឈ្មោះ [redacted] ចន្ថា បានទៅបុរីPT ដើម្បីធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិជាមួយខាងបុរី ដោយសារឈ្មោះ [redacted] ចន្ថា និងប្រពន្ធឈ្មោះ [redacted] ស មិនទាន់បង់ប្រាក់ផ្តាច់ជាមួយបុរីនោះទេ។ បន្ទាប់ពីធ្វើលិខិតផ្ទេរសិទ្ធិរួចខាងបុរីPT ក៏ធ្វើកិច្ចសន្យាលក់ដីឡូត៏-ផ្ទះវីឡា (អចលនទ្រព្យ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ជាមួយកូនក្តីខ្លួន ដោយលក់ក្នុងតម្លៃដើមចំនួន ៤៤,០០០ (បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក ដោយថ្ងៃនោះកូនក្តីខ្លួនបានបង់ប្រាក់បង្គ្រប់ឱ្យក្រុមហ៊ុនចំនួន ៣០,៨០០ (បីម៉ឺនប្រាំបីរយ) ដុល្លារអាមេរិក ប៉ុន្តែក្រុមហ៊ុនបានបញ្ចុះតម្លៃ ៣,០០០ (បីពាន់) ដុល្លារអាមេរិក ដោយសារកូនក្តីខ្លួនបង់ប្រាក់ផ្តាច់ ដូច្នេះនៅសល់ចំនួន ២៧,៨០០ (ពីរម៉ឺនប្រាំពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក។ នៅក្នុងកិច្ចសន្យាលក់ដីឡូត៍-ផ្ទះវីឡា (អចលនទ្រព្យ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមប្រការ៤ ថានឹងប្រគល់ផ្ទះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ រួមទាំងផ្ទេរសិទ្ធិកម្មសិទ្ធិពីឈ្មោះរបស់បុរីមកកូនក្តីខ្លួនវិញ។ ប៉ុន្តែរហូតដល់ពេលនេះផ្ទះមិនទាន់រួចទេ ហើយការផ្ទេរកម្មសិទ្ធិក៏មិនទាន់ធ្វើការផ្ទេរមកអោយកូនក្តីខ្លួនដែរ។ នៅក្នុងអំឡុងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ខាងបុរីបានឱ្យខ្លួនបង់ប្រាក់ថ្លៃធ្វើដំបូលផ្ទះ (ខ្លួនកែផ្ទះដោយខ្លួនឯង) ចំនួន ៤,៣០០ (បួនពាន់បីរយ) ដុល្លារអាមេរិក ទៀត ដោយមានលិខិតបញ្ជាក់ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ដូច្នេះលុយដែលខ្លួនបង់ទៅក្រុមហ៊ុនមានចំនួនសរុប ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក។ សំណូមពរសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់, សុំទាមទារសំណង និងជម្ងឺចិត្តដូចការទាមទាររបស់កូនក្តីទាំងស្រុង។

**<u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>**

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមអង្គសវនាការ, ផ្អែកតាមចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី និងអំណានចម្លើយរបស់ជនជាប់ចោទបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] ចាន់ធឿន ពិតជាបានប្រព្រឹត្តអំពើ ឆបោក ទៅលើជនរងគ្រោះឈ្មោះ [redacted] ប៉ុកឆាយ ដោយបានលក់ផ្ទះលេខ: D៥៤ ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ទៅឱ្យដើមបណ្តឹងឈ្មោះ [redacted] ប៉ុកឆាយ ក្នុងតម្លៃ ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក ហើយដើមបណ្តឹងឈ្មោះ[redacted] ប៉ុកឆាយ បានប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ហើយជនជាប់ចោទបានអះអាងថានឹងសាងសង់ផ្ទះឱ្យដើមបណ្តឹងឈ្មោះ [redacted] ប៉ុកឆាយ រួចរាល់ និងធ្វើវិញ្ញាបនប័ត្រ

សម្គាល់អចលនវត្ថុឱ្យឈ្មោះ [redacted] ប៉ុកឆាយ នៅខែមិថុនា ឆ្នាំ២០២១។ ផ្ទុយទៅវិញនៅពេលជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន បានទទួលប្រាក់ពីឈ្មោះ [redacted] ប៉ុកឆាយ គ្រប់ចំនួនហើយជនជាប់ចោទមិនបានធ្វើតាមការធានាអះអាងឡើយ ដោយផ្ទះមិនបានធ្វើ និងមិនទាន់ប្រគល់ប្លង់ផ្ទះឱ្យឈ្មោះ [redacted] ប៉ុកឆាយ នៅឡើយ។ អំពើរបស់ជនជាប់ចោទគឺជាអំពើដែលស្តែងឱ្យឃើញនូវសត្យានុម័តនៃបទល្មើសឆបោក គឺជាអំពើដែលប្រើប្រាស់ឋានៈក្លែង ក៏ដូចជាឧបាយកលផ្សេងៗ ដើម្បីទទួលបាននូវមូលនិធិតម្លៃ ឬក៏ទ្រព្យពីជនរងគ្រោះ។ ហេតុនេះតំណាងអយ្យការសុំរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៦១៣ អ.យ.គ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ ទុកជាបានការដដែល ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D៥៤ ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងប្តឹងសុំឱ្យតុលាការសម្រេចតាមច្បាប់។

**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការនេះឃើញថាៈ តាមចម្លើយរបស់កូនក្តីខ្លួនបានឆ្លើយមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែការចោទប្រកាន់ថា កូនក្តីខ្លួនបានគេចវេសពីការអនុវត្តតាមកិច្ចសន្យានោះគឺមិនពិតឡើយ ដោយហេតុថាកូនក្តីខ្លួនបានស្នើសុំឱ្យដើមបណ្តឹងដោះដូរផ្ទះទៅគម្រោងផ្សេងមួយទៀតដែលនៅក្បែរគ្នា ចំពោះគម្រោងផ្សេងនោះគឺធ្វើរួចរាល់ជាស្ថាពរហើយ។ ម្យ៉ាងវិញទៀតការមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាគឺជាវិវាទរដ្ឋប្បវេណីសុទ្ធសាធ ដែលនេះបញ្ជាក់ឱ្យឃើញថា កូនក្តីខ្លួនពុំមានប្រើឈ្មោះក្លែង ឬអះអាងទៅលើឋានៈក្លែង ឬប្រើឧបាយកលទុច្ចរិត ដែលនាំឱ្យខូចប្រយោជន៍ដល់បុគ្គលណាមួយឡើយ។ ហេតុដូច្នេះសំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ តាមបញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងតាមការសាកសួរដេញដោលនាពេលសវនាការនេះឃើញថាៈ ខ្លួនឯកភាពតាមសេចក្តីសន្និដ្ឋានរបស់សហការីទាំងស្រុង និងសុំបន្ថែមថា កូនក្តីខ្លួនពិតជាបានទទួលស្គាល់ថាការសាងសង់ពិតជាមានការយឺតយ៉ាវប្រាកដមែន ចំពោះទីតាំងដី និងផ្ទះរបស់ដើមបណ្តឹងនោះគឺពិតជាមានប្រាកដមែន។ អង្គហេតុនៃរឿងនេះគឺជាវិវាទរដ្ឋប្បវេណី ដែលមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាតែប៉ុណ្ណោះ។ ដូច្នេះស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទដោយក្តីអនុគ្រោះ។

**តុលាការ**

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបាន ស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបាន ពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។



Scanned with CamScanner

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជនជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D ៥៤ ភូមិឈ្ហាំង ឃុំឈ្ហាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ មានករណី ឆបោក មួយបានកើតមានឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ពិតប្រាកដមែន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស បានឆ្លើយសារភាពថាៈ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ អតិថិជនឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស បានមកទិញផ្ទះលេខ D៥៤ ផ្លូវបុរីPT ភូមិឈ្ហាំង ឃុំឈ្ហាំង ស្រុកពញាឮ ខេត្តកណ្តាល ដោយបានបង់ប្រាក់ចំនួន ៣០% ស្មើនឹងចំនួន ១៣,២០០ (មួយម៉ឺនបីពាន់ពីររយ) ដុល្លារអាមេរិក។ ក្រោយមកដោយគ្មានលទ្ធភាពបង់បន្តកិច្ចសន្យាជាមួយបុរី អតិថិជនឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស បានលក់ផ្ទះនេះបន្តទៅឱ្យឈ្មោះ [redacted] ប៉ុកឆាយ ដោយឈ្មោះ [redacted] ប៉ុកឆាយ បានបង់ប្រាក់ថ្លៃទិញផ្តាច់មកបុរីសរុបតម្លៃ ៤៨.៣០០ (បួនម៉ឺនប្រាំបីពាន់បីរយ) ដុល្លារអាមេរិក តែម្តង។ ដោយសារតែបញ្ហាជម្ងឺកូវីដ-១៩ និងបញ្ហាធ្លាក់ចុះនៃសេដ្ឋកិច្ច ធ្វើឱ្យការសាងសង់ផ្ទះនេះយឺតយ៉ាវ ស្រាប់តែអតិថិជនឈ្មោះ [redacted] ប៉ុកឆាយ បានដាក់ពាក្យបណ្តឹងមកតុលាការប្តឹងខ្លួនតែម្តង។ បច្ចុប្បន្នអថិជនជាច្រើនបានទទួលយកផ្ទះស្នាក់នៅ ហើយទទួលបានប្លង់មួយចំនួនរួចរាល់ហើយ ចំណែកផ្ទះរបស់ឈ្មោះ [redacted] ប៉ុកឆាយ បានសាងសង់រួចរាល់ ៧០% ហើយ។ ខ្លួនព្រមព្រៀងកាត់ប្លង់ជូនគាត់តាមនីតិវិធី សំណូមពរឱ្យគាត់មកចចារដោះស្រាយ ព្រោះខ្លួនអាចមានដំណោះស្រាយឱ្យគាត់ទទួលយកផ្ទះដែលសាងសង់រួច និងប្រគល់ប្លង់ជូនគាត់។

៤-តាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារភស្តុតាងដែលមាននៅក្នុងសំណុំរឿង មានលក្ខណៈច្បាស់លាស់អាចឱ្យតុលាការជឿបាន ពីព្រោះស៊ីសង្វាក់ទៅនឹងអង្គហេតុដែលបានកើតឡើង។ ដោយហេតុថា តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថាៈ ខ្លួនបានទិញផ្ទះលេខ D៥៤ បុរីPT ផ្លូវD ភូមិឈ្ហាំង ឃុំឈ្ហាំង ស្រុកពញាឮ ខេត្តកណ្តាល ពីឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស ក្នុងតម្លៃ ៥៥,០០០ (ប្រាំម៉ឺនប្រាំពាន់) ដុល្លារអាមេរិក តាមកិច្ចសន្យាទិញលក់អចលនវត្ថុ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ដោយសារឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស គ្មានលទ្ធភាពបង់ប្រាក់ទៅឱ្យបុរី។ នៅថ្ងៃនោះខ្លួន និងឈ្មោះ [redacted] ចន្ទា បានទៅបុរីPT ដើម្បីធ្វើការផ្ទេរសិទ្ធិកម្មសិទ្ធិជាមួយបុរី ដោយសារឈ្មោះ [redacted] ចន្ទា និងប្រពន្ធឈ្មោះ [redacted] ស មិនទាន់បង់ប្រាក់ផ្តាច់ជាមួយបុរីនោះទេ។ បន្ទាប់ពីធ្វើលិខិតផ្ទេរសិទ្ធិរួចខាងបុរីPT ក៏ធ្វើកិច្ចសន្យាលក់ដីឡូតិ៍-ផ្ទះវីឡា (អចលនទ្រព្យ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ជាមួយខ្លួន ដោយលក់ក្នុងតម្លៃដើមចំនួន ៤៤,០០០ (បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក ដោយថ្ងៃនោះខ្លួនបានបង់ប្រាក់បង្គ្រប់ឱ្យក្រុមហ៊ុនចំនួន ៣០,៨០០ (បីម៉ឺនប្រាំបីរយ) ដុល្លារអាមេរិក ប៉ុន្តែក្រុមហ៊ុនបានបញ្ចុះតម្លៃ ៣,០០០ (បីពាន់) ដុល្លារអាមេរិក ដោយសារខ្លួនបង់ប្រាក់ផ្តាច់ ដូច្នេះនៅសល់ចំនួន ២៧,៨០០ (ពីរម៉ឺនប្រាំពីរពាន់ប្រាំបី

រយ) ដុល្លារអាមេរិក។ នៅក្នុងកិច្ចសន្យាលក់ដីឡូត៍-ផ្ទះវីឡា (អចលនទ្រព្យ) ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមប្រការ៤ ថានឹងប្រគល់ផ្ទះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ រួមទាំងផ្ទេរសិទ្ធិកម្មសិទ្ធិពីឈ្មោះរបស់បុរីមកខ្លួនវិញ។ ប៉ុន្តែរហូតដល់ពេលនេះផ្ទះមិនទាន់រួចទេ ហើយការផ្ទេរកម្មសិទ្ធិក៏មិនទាន់ធ្វើការផ្ទេរមកឱ្យខ្លួនដែរ។ នៅក្នុងអំឡុងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ខាងបុរីបានឱ្យខ្លួនបង់ប្រាក់ថ្លៃធ្វើដំបូលផ្ទះ (ខ្លួនកែផ្ទះដោយខ្លួនឯង) ចំនួន ៤,៣០០ (បួនពាន់បីរយ) ដុល្លារអាមេរិក ទៀត ដោយមានលិខិតបញ្ជាក់ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ដូច្នេះលុយដែលខ្លួនបង់ទៅក្រុមហ៊ុនមានចំនួនសរុប ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក។ ដូចនេះតុលាការយល់ឃើញថា ជនជាប់ចោទខាងលើនេះពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៥-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស គឺជាអំពើ ឆបោក ដូចនេះមានភស្តុតាងដាក់បន្ទុក និងមានធាតុផ្សំបទល្មើសគ្រប់គ្រាន់។ ឃើញថានូវធាតុអត្តនោម័តគឺចេតនាប្រព្រឹត្តរបស់ជនជាប់ចោទបានប្រើល្បិចលួងលោម បញ្ចុះបញ្ចូលឱ្យជនរងគ្រោះមានការជឿជាក់យល់ព្រមទិញផ្ទះរបស់ខ្លួន និងធ្វើការប្រគល់ប្រាក់ឱ្យគ្រប់ចំនួន។ លុះដល់ថ្ងៃកំណត់ប្រគល់ផ្ទះ និងផ្ទេរកម្មសិទ្ធិជនជាប់ចោទពុំមានផ្ទះប្រគល់ឱ្យដើមបណ្តឹងឡើយ។ បន្ទាប់មកជនជាប់ចោទបានគេចវេសមិនទទួលខុសត្រូវនាំឱ្យខូចប្រយោជន៍របស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ជាធាតុសត្យានុម័ត។ ចំពោះធាតុនីត្យានុកូល អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជាបទល្មើសពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D៥៤ ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៦-តុលាការយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈសមហេតុសមផល។ គប្បីតុលាការទទួលមកពិនិត្យ ពិចារណា និងសម្រេចសេចក្តីតាមច្បាប់។

៧-តុលាការយល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណាឱ្យសមស្របតាមការប្តឹងសុំ។

៨-តុលាការយល់ឃើញថា សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទមានលក្ខណៈមិនសមហេតុសមផល។ គប្បីតុលាការមិនទទួលមកពិនិត្យពិចារណា និងសម្រេចសេចក្តីតាមច្បាប់។

៩-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជាសមត្ថជនដែលអាចយល់ដឹងនូវអំពើ និងបច្ច័យ ដែលកើតឡើងដោយសារអំពើរបស់ខ្លួន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវទោសព្រហ្មទណ្ឌ។ ការប្រព្រឹត្តរបស់ជនជាប់ចោទ បានពិចារណា និងយល់ដឹងនូវចំណងទាក់ទងហេតុ និងផលដែលជននេះប្រព្រឹត្តដោយចេតនា។ ដូច្នេះជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ។

១០-តាមសំអាងហេតុខាងលើ និងក្រោយពីបានពិចារណាទៅលើភស្តុតាង សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការរួចមក តុលាការបានរកឃើញនូវកំហុសរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន



Scanned with CamScanner

កេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជនជាតិខ្មែរ ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D៥៤ ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន។

១១-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន កេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជនជាតិខ្មែរ មានពិរុទ្ធភាពពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D៥៤ ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

១២-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន កេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ បានប្រព្រឹត្តជាបទមជ្ឈិម ដោយហេតុដើម្បីឱ្យជនជាប់ចោទក្លាយខ្លួនជាពលរដ្ឋដ៏ល្អនៅក្នុងសង្គមជាមនុស្សល្អវិញ គប្បីតុលាការពិចារណា ដោយប្រកាសទោសក្រោមកម្រិតអតិបរមានៃទោសដែលច្បាប់កំណត់តាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងព្យួរទោសធម្មតាទាំងមូល នៃទោសពន្ធនាគារឱ្យដល់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ព្រោះជនជាប់ចោទមិនទាន់មានការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេលប្រាំឆ្នាំមុនអំពើល្មើសនេះទេ។ម្យ៉ាងទៀតទោសដែលប្រកាសស្មើ ឬក្រោមប្រាំឆ្នាំទៀតផង។ ផ្អែកតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

១៣-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ កេទប្រុស អាយុ៣៤ឆ្នាំ បានសំណូមពរសុំទាមទារប្រាក់របស់ខ្លួនចំនួន ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក និងសុំទាមទារសំណងជំងឺចិត្តចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ គប្បីតុលាការពិចារណាក្នុងការសម្រេចពីសំណងនេះឱ្យបានសមស្របទៅនឹងព្យសនកម្មដែលបង្កឡើងដោយជនជាប់ចោទ។

១៤-ឃើញថាការប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដោយស្របតាមមាត្រា ១៤, មាត្រា ១៥, មាត្រា ២១ និងមាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអាចសម្រេចសំណងរដ្ឋប្បវេណីបាន ដោយផ្អែកតាមបទបញ្ញត្តិមាត្រា ២៣ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រោះថាតុលាការបានប្រកាសនូវពិរុទ្ធភាពលើជនជាប់ចោទជាមុន។

១៥-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ កេទប្រុស អាយុ៣៤ឆ្នាំ បានចូលមកបង្ហាញខ្លួននៅពេលសវនាការ ផ្អែកតាមមាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលក្រមនេះត្រូវជាសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី សាលក្រមនេះអាចប្ដឹងឧទ្ធរណ៍បាន។

១៦-ជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន កេទប្រុស មិនបានចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ហើយគ្មានកស្តុតាងបង្ហាញឱ្យឃើញថា ជនជាប់ចោទបានដឹងពីការកោះហៅនេះដែរ ដូច្នេះសាលក្រមនេះជាសាលក្រមកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទ តាមមាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ (អាចប្ដឹងទាស់បាន)

## **ហេតុដូច្នេះសម្រេច**

១-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន កេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងមូល តាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចផ្ទះលេខ D៥៤ ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៨២ ជនជាតិខ្មែរ បង់សងសំណងការខូចខាតទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ ភេទប្រុស អាយុ៣៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៥ ភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាប្រាក់ចំនួន ៤៥,៣០០ (បួនម៉ឺនប្រាំពាន់បីរយ) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល។ ការទាមទារលើសពីនេះត្រូវបដិសេធចោល។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង០២ និង៣០នាទីរសៀល ដោយចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៉ុកឆាយ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ធឿន។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] |

---

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| **ចៅក្រមជំនុំជម្រះ** | ថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ |
| | រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |

Scanned with CamScanner